Department of Primary Industries

ប័ណ្ណពត៌មាន 6

# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## នីតិវិធីការងារ

Virginia Brunton & Jeremy Badgery-Parker, Ourimbah

គឺជាការសំខាន់ដែលត្រូវមានការត្រួតពិនិត្យ ហើយធ្វើតាមនីតិវិធីការងារនៅលើចំការ ធ្វើឲ្យហានិភ័យដោយសារមនុស្សដែលនឹងនាំយកបញ្ហាមកដាក់ក្នុងដំណាំមានតិចបំផុត។ នីតិវិធីការងារដែលបានកំណត់ការអនុវត្តន៍យ៉ាងច្បាស់លាស់ ហើយកិច្ចការតាមលំដាប់លំដោយអាចធ្វើឲ្យប្រសិទ្ធិភាពកើនឡើង សន្សំសំចៃប្រាក់ និងធ្វើឲ្យការគ្រប់គ្រងលើសត្វចង្រៃ និងជម្ងឺបានប្រសើរឡើង។

### នីតិវិធីការងារ

នីតិវិធីការងារ ចាំបាច់ត្រូវបង្ហាញឲ្យដឹងអំពីគ្រប់កិច្ចការដែលពាក់ព័ន្ធក្នុងការធ្វើការងារក្នុងដំណាំ ឬលើទីវាល (ឧទាហរណ៍ ការដាំបណ្តុះ) ក៏ដូចជានៅពេលធ្វើដំណើរទៅមករវាងដំណាំ និងរចនាសម្ព័ន្ធដទៃទៀតដែរ ដូចជាកន្លែងដាំបណ្តុះ និងលក់កូនឈើតូចៗជាដើម។ រឿងដែលមានប្រយោជន៍អំពីនីតិវិធីការងារគឺថាដោយបានកត់វាទុកមួយ វាជួយលោកអ្នកឲ្យគិតអំពីអ្វីដែលលោកអ្នកកំពុងធ្វើ ឬស្នើសុំឲ្យអ្នកណាម្នាក់ទៀតធ្វើ ហេតុអ្វីបានជាលោកអ្នកធ្វើវា ហើយតើវាពាក់ព័ន្ធនឹងហានិភ័យអ្វីខ្លះ។

មានកិច្ចការផ្សេងៗគ្នាជាច្រើនដែលចាំបាច់ត្រូវបំពេញវាឲ្យហើយ នៅជុំវិញចំការ។



នីតិវិធីការងារចាំបាច់ត្រូវបង្កើតឡើងដើម្បីបង្ហាញឲ្យដឹងអំពីការងារនីមួយៗ និងគ្រប់ការងារទាំងអស់។ ថ្វីដ្បិតតែវាអាចហាក់ដូចជាមានការងារច្រើននៅគ្រាដំបូងក៏ដោយ នីតិវិធីការងារសន្សំសំចៃពេលវេលា និងប្រាក់ នឹងកាត់បន្ថយហានិភ័យនៃការប្រឈមមុខនឹងបញ្ហា។ ជាញឹកញាប់ លោកអ្នកពុំត្រូវការវាច្រើនជាងពីរបីបន្ទាត់ ឬចំណុចឡើយ ដើម្បីពិពណ៌នាអំពីអ្វីដែលត្រូវកើតឡើង និងភាពទៅតាមលំដាប់លំដោយណាមួយ។

នីតិវិធីការងារលើចំការទូទៅ អាច សម្គាល់ដឹងថាផ្លូវថ្នល់តំបន់នៅចន្លោះរវាងតំបន់ មានដំណាំ

ឬបំពង់នាំទឹកបាញ់ស្រោចដំណាំ ត្រូវរក្សាវាឲ្យស្អាត និងកុំឲ្យមានរុក្ខជាតិ និងកំទេចសំណល់រុក្ខជាតិ ហើយចំណុចឆែកឆេរ និងត្រួតពិនិត្យត្រូវបានអនុវត្តចំពោះការចូល ក្នុងតំបន់ "ស្អាត" ឬការចូលទៅក្នុងដំណាំ។ កិច្ចការដែលត្រូវបង្ហាញឲ្យដឹងតាមនីតិវិធីការងារអាចមានរួមទាំង:

- ការពិនិត្យតាមដានសត្វល្អិតចង្រៃ និងជម្ងឺ
- ការត្រួតពិនិត្យលើការបាញ់ស្រោចទឹក
- ការចាត់ចែងធ្វើតេស្តដី ដូចជាការវាស់ស្ទង់កំរិត ផះ និងភាពចម្លងចរន្តអគ្គីសនី(ចំនួនអំបិលដែលរលាយក្នុងទឹក) ជាដើម
- ការរៀបចំនៅលើទីដី
- ការដាំបណ្តុះ
- រៀបចំការបាញ់ស្រោចទឹក
- ការដាក់ជីដំណាំ និងជ្រុំគល់ដំណាំដាក់ជី
- ការគ្រប់គ្រងលើរុក្ខជាតិតូចៗឥតប្រយោជន៍
- ការអនុវត្តន៍បាញ់ព្រួសទឹក
- លាបថ្នាំពណ៌ក្រហមចំពោះរុក្ខជាតិដែលមានជម្ងឺ
- ការច្រូតកាត់ប្រមូលផល
- ការលាងសំអាត និងវេចខ្ចប់ផលដំណាំ
- ការធ្វើដំណើរជុំវិញចំការ
- ចលនាទៅក្នុងចំការនៃមនុស្ស និងយានយន្តដែលធ្លាប់នៅក្នុងចំការដទៃទៀត ឧទាហរណ៍ អ្នកផ្តល់ការពិគ្រោះយោបល់អំពីដំណាំ
- ការដឹកជញ្ជូនកាកសំណល់ដំណាំ
- ការដាំបណ្តុះក្រោយពេលច្រូតកាត់ប្រមូលផល
- ការទទួលការប្រគល់គ្រឿងសម្ភារៈ
- ការរក្សាទុកតំបន់ នៅចន្លោះរវាងតំបន់មានដំណាំ

- ការច្រូតកាត់ស្មៅ
- ការហ្វឹកហ្វឺនអំពីការកាត់មែកឈើ ឬកាត់ដើមវល្លិ៍
- ការដឹកយកផលដំណាំទៅរោងសំរាប់វេចខ្ចប់
- ការលាងសំអាត និងសម្លាប់មេរោគលើឧបករណ៍ប្រើប្រាស់ និងគ្រឿងម៉ាស៊ីន
- អនាម័យនៃបុគ្គលិកធ្វើការលើទីវាល។

នីតិវិធីការងារគួរសម្គាល់ឲ្យដឹង អំពីលំដាប់លំដោយនៃដំណាំដែលគេធ្វើការជាមួយ របៀបណាដែលដំណាំនឹងត្រូវបានគ្រប់គ្រង និងអ្វីដែលជាគោលដៅនៃស្ថានភាពដាំដុះ។ នីតិវិធីការងារក៏គួរផ្តល់ពត៌មានពិស្តាដែលពិពណ៌នាអំពីរបៀបណាដែលកិច្ចការត្រូវបានធ្វើ (ឧទាហរណ៍ របៀបណាដែលត្រូវចាត់ចែងការឆែករកមើលសត្វចង្រៃ) និងតើត្រូវធ្វើអ្វីខ្លះ ប្រសិនបើបញ្ហាត្រូវបានគេរកឃើញ (ឧទាហរណ៍ តើត្រូវរាយការណ៍របៀបណាអំពីសត្វចង្រៃនៅលើទីវាល)។

នីតិវិធីការងារអាចមានលក្ខណៈសាមញ្ញដូចជាការចែងថា ទីវាលត្រូវបានធ្វើការតាមលំដាប់លំដោយការងារដែលបានរាយឈ្មោះ ហើយថាត្រូវឆែកមើលបញ្ជីរាល់ថ្ងៃមុននឹងចាប់ផ្តើមធ្វើការងារ។ ឧទាហរណ៍ អាចសរសេរបញ្ជីនេះនៅពីលើក្តារខៀនដ៏ធំមួយក្នុងរោងសំរាប់វេចខ្ចប់។ តាមរបៀបនេះ លំដាប់លំដោយការងារអាចត្រូវបានផ្លាស់ប្តូរនៅពេលណាគេត្រូវការ (ដូចជានៅពេលដែលការកើតឡើងយ៉ាងទាន់ហន់នៃជម្ងឺ ត្រូវបានគេរកឃើញនៅលើទីវាលមួយ ជាដើម) ហើយដែលងាយស្រួលពិនិត្យមើលដោយបុគ្គលិកទាំងអស់ ឬដោយអ្នកធ្វើការក្រោមកិច្ចសន្យា។

នីតិវិធីការងារតាមលំដាប់លំដោយដែលមានប្រសិទ្ធិភាព ពាក់ព័ន្ធនឹងការធ្វើការងារនៅក្នុងដំណាំដែលស្អាតបំផុតមុនគេ រួចហើយដំណាំដែលស្អាតបំផុតបន្ទាប់ ហើយបន្តធ្វើដូចគ្នានេះតទៅទៀត។ ដោយធ្វើដូចនេះ ឱកាសសំរាប់ឆ្លងរាលដាលបញ្ហាត្រូវបានកាត់បន្ថយឲ្យមានតិច។

បញ្ជីការងារតាមលំដាប់លំដោយ ចាំបាច់ត្រូវរក្សាឲ្យទាន់ពេល ដោយយោងទៅតាមសត្វល្អិតចង្រៃ និងជម្ងឺអ្វីខ្លះដែលគេរកឃើញក្នុងដំណាំនីមួយៗ។ ពេលណាពុំមានការសង្កេតរកមើលសត្វចង្រៃ ឬជម្ងឺក្នុងចំការណាមួយទេ លំដាប់លំដោយការងារចាំបាច់ត្រូវតែចាប់ធ្វើ ពីដំណាំខ្ចីបំផុត មកដល់ដំណាំចាស់បំផុត។

គំរោងការងារតាមលំដាប់លំដោយដែលសាមញ្ញ:

- ធ្វើការក្នុងដំណាំដែលស្អាតបំផុតមុនគេ
- ធ្វើការក្នុងដំណាំដែលខ្ចីបំផុតមុនគេ
- ធ្វើកិច្ចការដែល "ក្រខ្វក់ " ទាំងអស់ ចុងក្រោយគេ ក្នុងមួយថ្ងៃៗ
- កុំធ្វើការក្នុងដំណាំនៅពេលស្លឹកវាសើម និងនៅពេលដែលជម្ងឺលើស្លឹកបានបង្ហាញឲ្យឃើញ។

គឺជាការសំខាន់ដែលត្រូវធ្វើឲ្យប្រាកដច្បាស់ថាដំណាំ ឬទីវាលទាំងអស់មានអាទិភាពសំរាប់ការងារទាំងអស់ មានរួមទាំងកិច្ចការត្រួតពិនិត្យ និងការបាញ់ស្រោចទឹក ក៏ដូចជាសកម្មភាពគ្រប់គ្រងលើរុក្ខជាតិទូទៅដែរ។ ប្រសិនបើកន្លែងដំណាំ ឬទីវាលមានការកើតឡើងយ៉ាងទាន់ហន់នៃសត្វចង្រៃ ឬជម្ងឺ កន្លែងដែលបានឆ្លងរោគ គួរតែជាកន្លែងចុងក្រោយដែលគេបានធ្វើការលើក្នុងដំណាំនោះ។

ប្រសិនបើការកើតមានសត្វចង្រៃទាំងហ្វូង ឬរុក្ខជាតិមានជម្ងឺជាច្រើនត្រូវបានគេរកឃើញនៅក្នុងដំណាំ ក្នុងអំឡុងពេលមានសកម្មភាពការងារ ការនេះត្រូវតែរាយការណ៍ ហើយបញ្ជីការងារតាមលំដាប់លំដោយ ចាំបាច់ត្រូវពិនិត្យមើលសារជាថ្មី។

> *" ត្រូវរៀបចំសកម្មភាពទាំងឡាយក្នុងកាលវិភាគ ក្នុងដំណាំដែលមានសត្វចង្រៃតិចបំផុត មុននឹងធ្វើការងារលើដំណាំដែលមានសត្វចង្រៃច្រើន"*

នៅពេលការងារត្រូវបានបំពេញរួច ក្នុងដំណាំដែលមានសត្វចង្រៃច្រើន ឬដំណាំដែលមានជម្ងឺ (ឬផ្នែកមួយនៃដំណាំ) នីតិវិធីការងារចាំបាច់ត្រូវឲ្យប្រាកដថាគ្រឿងឧបករណ៍ និងគ្រឿងម៉ាស៊ីនទាំងអស់បានត្រូវលាងសំអាត និង/ឬសម្លាប់មេរោគ ហើយសម្លៀកបំពាក់បានត្រូវផ្លាស់ប្តូរ (ឬខោអៀម និងគម្របស្បែកជើងកវែងត្រូវបានប្តូរចេញ) មុននឹងមនុស្សចូលទៅក្នុងដំណាំបន្ទាប់។ ក្នុងស្ថានភាពខ្លះ ប្រដាប់ត្រាំជើងអាចមានប្រយោជន៍សំរាប់កាត់បន្ថយការឆ្លងរាលដាលជម្ងឺ ដែលបង្ករឡើងដោយដីរវាងប្លុកដំណាំផ្សេងគ្នា និងជម្ងឺដែលមនុស្សខាងក្រៅនាំមកលើទីកន្លែង។

ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពី រក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រងសត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយនេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្តី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្តីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើ មានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារសមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្តល់ឱវាទឯករាជ្យសំរាប់អ្នកប្រើប្រាស់។ ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួង ពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT 12/24529

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបាន ទទួលការផ្គត់ផ្គង់ប្រាក់មួយចំណែកពីគំរោងដែលទទួល ប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្ត្រាលី):

Horticulture Australia

*ការដោះស្រាយអំពីគុណភាព*
*ងសុវត្ថិភាពនៃផលិតផលជ*
*ាមួយអ្នកដាំដុះនៃឧស្សាហកម្ម*
*បន្លែដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស*
ការផ្តើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្ម បន្លែ។